# របាយការណ៍សង្ខេប
# របស់ឯកឧត្តម ងួន រតនៈ អភិបាល នៃគណៈអភិបាលខេត្តកំពង់ធំ
# ស្តីពីភាពជោគជ័យរយៈពេល៥ឆ្នាំកន្លង របស់រដ្ឋបាលខេត្តកំពង់ធំ

ថ្ងៃអង្គារ ៩រោច ខែមាឃ ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦

ថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០២២

- សូមក្រាបថ្វាយបង្គំព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គ ជាទីគោរពសក្ការៈ!
- សូមគោរព សម្តេច ឯកឧត្តម លោកជំទាវ ជាទីគោរព !
- បងប្អូនអ្នកសារព័ត៌មានជាតិ អន្តរជាតិ និងភ្ញៀវកិត្តិយសទាំងអស់ជាទីមេត្រី !

ជាបឋមក្នុងនាមរដ្ឋបាលខេត្ត និងក្នុងនាមខ្លួនខ្ញុំផ្ទាល់ ខ្ញុំសូមថ្លែងអំណរគុណ ដល់អង្គភាពអ្នកនាំពាក្យរាជរដ្ឋាភិបាលដែលបានផ្តល់ឱកាសឲ្យរដ្ឋបាលខេត្តកំពង់ធំបានធ្វើបទបង្ហាញអំពីភាពជោគជ័យរយៈពេល ៥ឆ្នាំ របស់ខេត្តកំពង់ធំ ។ ខ្ញុំបាទក៏សូមយកឱកាសនេះសម្តែងនូវការគោរព និងថ្លែងអំណរគុណដ៏ខ្ពង់ខ្ពស់ជូនចំពោះសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ដែលបានដឹកនាំការអនុវត្តយុទ្ធសាស្ត្រចតុកោណគ្រប់ដំណាក់កាលសម្រេចបាននូវផ្លែផ្កាគួរជាទីមោទនៈបំផុត ។ កម្ពុជាក្រោមការដឹកនាំរបស់ប្រមុខរាជរដ្ឋាភិបាលដែលមានចក្ខុវិស័យខ្ពស់ កំពុងប្រែខ្លួនពីប្រទេសដែលមានចំណូលមធ្យមកម្រិតទាប ទៅជាប្រទេសដែលមានចំណូលមធ្យមកម្រិតខ្ពស់ និងកំពុងកសាងមូលដ្ឋានដ៏រឹងមាំឆ្ពោះទៅសម្រេចចក្ខុវិស័យកម្ពុជាឆ្នាំ២០៥០ ។ ជាមួយនឹងសមិទ្ធផលដ៏ត្រចះត្រចង់នេះ ខេត្តកំពង់ធំ ក៏ទទួលបាននូវការអភិវឌ្ឍ រីកចម្រើនស្ទើរគ្រប់វិស័យផងដែរ ដែលរួមមានទាំងការអភិវឌ្ឍធនធានមនុស្ស ការរីកចម្រើនហេដ្ឋារចនាសម្ព័ន្ធផ្សេងៗ ស្របតាមយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤របស់រាជរដ្ឋាភិបាល។ ដើម្បីឲ្យកាន់តែយល់ច្បាស់អំពីសមិទ្ធផលសំខាន់ៗ ដែលខេត្តកំពង់ធំសម្រេចបានក្នុងរយៈពេល៥ឆ្នាំកន្លងទៅនេះ ខ្ញុំបាទសូមធ្វើសេចក្តីរាយការណ៍ជូនអង្គសន្និសីទដោយសង្ខេបដូចខាងក្រោម ៖

## I- ស្ថានភាពទូទៅ

ខេត្តកំពង់ធំ ស្ថិតនៅចំកណ្តាលនៃព្រះរាជាណាចក្រកម្ពុជា មានចម្ងាយ ១៦៨គីឡូម៉ែត្រ ពីរាជធានីភ្នំពេញ មានព្រំប្រទល់ជាប់ខេត្តព្រះវិហារ ស្ទឹងត្រែង ក្រចេះ កំពង់ចាម កំពង់ឆ្នាំង ពោធិ៍សាត់ និងសៀមរាប **បែកជាក្រុង០១ ស្រុក០៨ ឃុំ៧៣ សង្កាត់០៨ ភូមិ៧៦៧** ដែលមានប្រជាពលរដ្ឋចំនួន **១៨៤.១៧៩គ្រួសារ** ស្មើនឹង **៨៤៣.៦៤៤នាក់ ស្រី៤២៧.៦៣០នាក់ ដង់ស៊ីតេប្រជាពលរដ្ឋ ៥៦នាក់/គ.ម²** ។ ខេត្តមានផ្ទៃដីសរុបចំនួន **១៥.០៦១គ.ម²** ស្មើនឹង **១.៥០៦.១៩៧ហ.ត** ។

## II- សមិទ្ធផលសំខាន់ៗរបស់រដ្ឋបាលខេត្តរយៈពេល៥ឆ្នាំ

### ១. ការងារសន្តិសុខសណ្តាប់ធ្នាប់

រដ្ឋបាលខេត្តបានខិតខំបំផុសចលនាឲ្យមានការចូលរួមពីមូលដ្ឋានក្នុងការអនុវត្តគោលនយោបាយភូមិ ឃុំ មានសុវត្ថិភាព ដើម្បីរួមគ្នារក្សាការពារសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ និងសុវត្ថិភាពសង្គមបានល្អ ។ ក្នុង

នោះ បទល្មើសព្រហ្មទណ្ឌ គ្រឿងញៀន ល្បែងស៊ីសងគ្រប់ប្រភេទបានថយចុះ ។ ផ្តើមចេញពីចំណុចនេះ ធ្វើឲ្យការអនុវត្តគោលនយោបាយភូមិ ឃុំ មានសុវត្ថិភាព ទទួលបានលទ្ធផលល្អប្រសើរក្នុងការចូលរួមប្រឡងប្រណាំងទូទាំងប្រទេសដោយ ក្នុងឆ្នាំ២០២២កន្លងទៅនេះ ឃុំ សង្កាត់ទាំង៨១ ទទួលបានចំណាត់ថ្នាក់ទាំងអស់ ក្នុងនោះចំណាត់ថ្នាក់លេខ១ មានចំនួន ៧៤ឃុំ-សង្កាត់ ចំណាត់ថ្នាក់លេខ២ ចំនួន ៥ឃុំ-សង្កាត់ និងចំណាត់ថ្នាក់លេខ៣ ចំនួន ២ឃុំ ។

**២.ការផ្តល់សេវាសាធារណៈ**

មកទល់បច្ចុប្បន្ននេះ រដ្ឋបាលខេត្តកំពង់ធំ បានរៀបចំដាក់ដំណើរការអង្គភាពច្រកចេញចូលតែមួយខេត្ត និងការិយាល័យច្រក ចេញចូលតែមួយបានគ្រប់ក្រុង/ស្រុក រហូតដល់ថ្នាក់ឃុំ/សង្កាត់ ។ ជាលទ្ធផល ក្នុងរយៈពេល៥ឆ្នាំនេះ អង្គភាពច្រកចេញចូលតែមួយរបស់រដ្ឋបាលខេត្តបានផ្តល់សេវាសរុបចំនួន **១៩៨.៦៥៨សេវា** ស្មើនឹងថវិកាចំនួន **៨.៥៣៧.១៣០.៤៥៧រៀល** ។ គួរកត់សម្គាល់ផងដែរថា ក្នុងរយៈពេល២ឆ្នាំចុងក្រោយនេះ អង្គភាពច្រកចេញចូលតែមួយរដ្ឋបាលខេត្តកំពង់ធំត្រូវបានផ្តល់ចំណាត់ថ្នាក់លេខ១ ជាភ្នាក់ងារដែលបានផ្តល់សេវាបានច្រើនជាងគេទូទាំងប្រទេសផងដែរ ។ លើសពីនេះ អគាររដ្ឋបាលឃុំ/សង្កាត់ក៏ត្រូវបានសាងសង់បានគ្រប់ឃុំ/សង្កាត់ទូទាំងខេត្ត ដើម្បីជំរុញការផ្តល់សេវាសាធារណៈ នៅមូលដ្ឋានឲ្យកាន់តែមានភាពងាយស្រួលជូនប្រជាពលរដ្ឋ និងធានាឲ្យបាននូវប្រសិទ្ធភាពក្នុងការថែរក្សាឯកសារអត្រានុកូលដ្ឋាន និងឯកសារចាំបាច់នានា ។

**៣.ការអនុវត្តកិច្ចគាំពារសង្គម**

ឆ្លើយតបទៅនឹងសម្ពាធសេដ្ឋកិច្ចដែលកើតចេញពីវិបត្តិជំងឺកូវីដ១៩ រាជរដ្ឋាភិបាលបានដាក់ចេញនូវកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារក្រីក្រ និងងាយរងគ្រោះ ដើម្បីស្តារលទ្ធភាព និងជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ ។ ក្នុងនោះដែរ ខេត្តកំពង់ធំបានឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារក្រីក្រដែលរងផលប៉ះពាល់ដោយជំងឺកូវីដ១៩បានចំនួន **៤៣.០៤៧គ្រួសារ** ស្មើនឹងទឹកប្រាក់ **២១០.៩៩១.៤៤៨.០០០រៀល** ។ ជាមួយគ្នានេះ ខេត្តក៏បានឧបត្ថម្ភសាច់ប្រាក់ជូនស្ត្រីមានផ្ទៃពោះ និងកុមារអាយុក្រោម ២ឆ្នាំបានចំនួន **១០.២៣៩នាក់** ស្មើនឹងទឹកប្រាក់ **៣.៩៧២.៣២០.០០០រៀល** ។ ខេត្តក៏បានផ្តល់ប្រាក់ឧបត្ថម្ភបន្ថែមរបស់រាជរដ្ឋាភិបាលសម្រាប់កម្មករនិយោជិតជាស្ត្រីនៅពេលសម្រាលកូនបានចំនួន **៥.៧៧៤នាក់** សរុបជាទឹកប្រាក់ **២.៣០៩.៦០០.០០០រៀល** ។

**៤.ការអនុវត្តគម្រោងហេដ្ឋារចនាសម្ព័ន្ធ**

ក្រៅពីសមិទ្ធផលខាងលើនេះ រដ្ឋបាលខេត្តបានអនុវត្តគម្រោងគុណប្រយោជន៍ និងគម្រោងអភិវឌ្ឍន៍ ៣ឆ្នាំរំកិលបានចំនួន **៨៥គម្រោង** ក្នុងនោះសម្រេចបាននូវសមិទ្ធផលសំខាន់ៗ ដូចជា សាងសង់ទីធ្លាចំណត **០៥កន្លែង** សួនច្បារសាធារណៈ **១២កន្លែង** រូបសំណាក **០៩កន្លែង** សាងសង់ច្រាំងស្ទឹង **៧៥៥ម** ភ្លើងបំភ្លឺក្នុងទីប្រជុំជន **៨៥៣បង្គោល** និងភ្លើងស្តុប និងភ្លើងសញ្ញាប្រុងប្រយ័ត្ន **៣០ដើម** ។

**៥.ការអនុវត្តគោលនយោបាយតាមបទបញ្ជាដ៏ខ្ពង់ខ្ពស់របស់សម្តេចតេជោ**

អនុវត្តតាមអនុសាសន៍ណែនាំ និងបទបញ្ជាដ៏ខ្ពង់ខ្ពស់របស់សម្តេចតេជោនាយករដ្ឋមន្ត្រី រដ្ឋបាលខេត្តបានយកចិត្តទុកដាក់ និងសម្រេចបានលទ្ធផលដូចខាងក្រោម ៖

- បានធ្វើការកែសម្រួលព្រំប្រទល់ដីពីតំបន់២ មកតំបន់១ ជូនប្រជាពលរដ្ឋចំនួន **១០.៨០៣គ្រួសារ** ស្មើនឹង **១៧.៣៣៩ហ.ត**

- បានធ្វើការសម្រួលផ្ទៃដីពីតំបន់៣ មកតំបន់២ ជូនប្រជាពលរដ្ឋចំនួន **៨.៦៦១គ្រួសារ** ស្មើនឹង **៣៤.១៥៩ហ.ត**
- បានកំណត់តំបន់ទ្រនាប់នៃដែនព្រៃលិចទឹក(តំបន់២) នៃតំបន់ទន្លេសាបក្នុងខេត្តកំពង់ធំ ទំហំ **១២១.៤០២ហ.ត**
- រដ្ឋបាលខេត្តក៏បានស្នើសុំកាត់ឆ្វៀលដីចេញគម្រប់ព្រៃឈើ២០០២ និងដីសហគមន៍ ផ្ទៃដីទំហំ **១៦១.៤៣៩,១៤ហ.ត** ស្មើនឹង **៤៦.៥៣៣គ្រួសារ** និងបានស្នើសុំកាត់ឆ្វៀលដីតំបន់ការពារបរិស្ថានក្នុងខេត្តកំពង់ធំ ទំហំ **៦២.៨៨៣ហ.ត** ស្មើនឹង **១៥.៧២៩គ្រួសារ**
- ដោយឡែក ពាក់ព័ន្ធនឹងការបង្ក្រាបបទល្មើសជលផល រដ្ឋបាលខេត្តបានរៀបចំទីបញ្ជាការស្រាល និងដាក់ក្រុមការងារប្រចាំការ ដោយសហការជាមួយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដើម្បីបង្ក្រាបបទល្មើសជលផលលើបឹងទន្លេសាប ក្នុងភូមិសាស្ត្រឃុំផាត់សណ្តាយ ស្រុកកំពង់ស្វាយ និងឃុំពាមបាង ស្រុកស្ទោង ។

## III- **ការងារកសិកម្ម និងធារាសាស្ត្រកសិកម្ម**

ខេត្តកំពង់ធំមានផ្ទៃដីដាំដុះស្រូវសរុបចំនួន **២៥៣.៣០០ហ.ត** ទិន្នផលជាមធ្យម ៤តោន/ហិកតា។ ឡសម្ងួតស្រូវមានចំនួន **៣០ឡ** មានសមត្ថភាពសម្ងួតបាន ៣ តោន/ម៉ោង ។ ជារួមក្នុងរយៈពេល៥ឆ្នាំនេះ ខេត្តកំពង់ធំផលិតបានស្រូវក្នុងរង្វង់ **៦០-៧០ម៉ឺនតោន**ក្នុងមួយឆ្នាំ ដែលអាចបំពេញតម្រូវការស្បៀងបានគ្រប់គ្រាន់ និងនៅសល់ស្រូវសម្រាប់នាំចេញប្រមាណ **៥០ម៉ឺនតោន** ។

ខេត្តមានរោងចក្រកែច្នៃជ័រកៅស៊ូចំនួន ០៨ ក្នុងចំណោម ២៧ក្រុមហ៊ុន ដែលមានផ្ទៃដីកៅស៊ូដាំដុះសរុបចំនួន **៥៣.៩៨៤ហ.ត** (ចៀជ័របាន **៤៧.៤៦៨ហ.ត**) និងកៅស៊ូគ្រួសារ **៨.៥៦៣,២១ហ.ត** (ចៀជ័រ **៨.៥៦៣ហ.ត**) ដោយស្រូបយកកម្លាំងពលកម្មពីតំបន់ផ្សេងៗចំនួន **១១.៨៤១នាក់** ។

ក្រៅពីនេះ ខេត្តមានផ្ទៃដីដាំដុះដំណាំកសិឧស្សាហកម្មដូចជា ដំណាំចន្ទីដាំដុះបាន **១១៧.៩៩០ ហ.ត** ដំឡូងមី **៥៣.៣៨៤ហ.ត** ស្វាយកែវរមៀត **៨.៤៥៧ហ.ត** ម្រេច **១៤១ហ.ត** និងតាដែន **៧៥ហ.ត** ។ ជាមួយគ្នានេះ ខេត្តក៏មានរោងម៉ាស៊ីនកែច្នៃគ្រាប់ស្វាយចន្ទី **០៤កន្លែង** និងម៉ាស៊ីនសម្ងួត **២៣កន្លែង** ។

ជាមួយនឹងការរីកចម្រើននៃវិស័យកសិកម្មខាងលើ ខេត្តបានសាងសង់ និងជួសជុលប្រព័ន្ធធារាសាស្ត្រចំនួន **២៦១កន្លែង** ក្នុងនោះមានប្រព័ន្ធធារាសាស្ត្រធំៗចំនួន **០៣កន្លែង** ដែលអាចស្រោចស្រពស្រូវវស្សា **១៣៣.១៦៩ហ.ត** ស្មើនឹង **៦២%** និងស្រូវប្រាំង **២៥.០៩៦ហ.ត** ស្មើនឹង **៦៣%** ។ លើសពីនេះ ខេត្តមានប្រភពទឹកសំខាន់ៗដូចជា ស្ទឹងសែន ស្ទឹងស្ទោង ស្ទឹងតាំងក្រសាំង និងស្ទឹងជីនិត ដែលសរុបជាផ្ទៃរងទឹកភ្លៀងទំហំ **២.៨៩៣.៣២៨ហ.ត** ។

## IV- **ការងារទេសចរណ៍**

ខេត្តកំពង់ធំមានរមណីយដ្ឋានទេសចរណ៍សំខាន់ៗចំនួន **១៤កន្លែង** ក្នុងនោះរមណីយដ្ឋានដែលទាក់ទាញភ្ញៀវទេសចរណ៍បានច្រើនជាងគេគឺ រមណីយដ្ឋានវប្បធម៌ប្រវត្តិសាស្ត្រ ប្រាសាទសំបូរព្រៃគុក (ដែលបានចុះក្នុងបញ្ជីបេតិកភណ្ឌពិភពលោក កាលពីថ្ងៃទី ០៨ កក្កដា ឆ្នាំ២០១៧ នៅទីក្រុង Krakow ប្រទេសប៉ូឡូញ) រមណីយដ្ឋានវប្បធម៌ប្រវត្តិសាស្ត្រប្រាសាទគុកនគរ រមណីយដ្ឋានវប្បធម៌ធម្មជាតិភ្នំសន្ទុក រមណីយដ្ឋានធម្មជាតិស្ទឹងព្រៃប្រស់ រមណីយដ្ឋានកែច្នៃបឹងសំរឹទ្ធិ និងរមណីយដ្ឋានកែច្នៃស្ទឹងជីនិត ។ ក្រៅពីនេះ ខេត្តក៏មាន

សហគមន៍ទេសចរណ៍ និងអេកូទេសចរណ៍ចំនួន **១៤កន្លែង** និងរមណីយដ្ឋានកសិទេសចរណ៍ **០១កន្លែង** ផងដែរ ។ ចំណែកសេវាផ្សេងៗទៀតដែលបម្រើដល់វិស័យទេសចរណ៍មានដូចជា សណ្ឋាគារចំនួន **០៨កន្លែង** ផ្ទះសំណាក់ **៨៣កន្លែង** និងភោជនីយដ្ឋាន/អាហារដ្ឋានចំនួន **១១៥កន្លែង** ។

នៅរយៈពេល៥ ឆ្នាំកន្លងទៅនេះ ខេត្តកំពង់ធំបានទទួលភ្ញៀវទេសចរសរុបចំនួន **១.៣០០.៨៤៦**នាក់ ក្នុងនោះ ភ្ញៀវទេសចរជាតិចំនួន **១.២៤០.៤៩០**នាក់ និងភ្ញៀវទេសចរអន្តរជាតិចំនួន **៦០.៣៥៦**នាក់ ។ មុនវិបត្តិជំងឺកូវីដ១៩ ភ្ញៀវទេសចរណ៍មកទស្សនាខេត្តមានប្រមាណ ៣០ម៉ឺននាក់ក្នុងមួយឆ្នាំ តែក្នុងឆ្នាំ២០២០ - ២០២១ ភ្ញៀវទេសចរណ៍បានធ្លាក់ចុះយ៉ាងគំហុក មកត្រឹមប្រមាណ ៦ម៉ឺននាក់ក្នុង១ឆ្នាំ ។ ក្រោយពីការបើកប្រទេសឲ្យដំណើរជាប្រក្រតីឡើងវិញ វិស័យទេសចរណ៍ក្នុងខេត្តកំពង់ធំបាន និងកំពុងវិលត្រលប់មកភាពល្អប្រសើរឡើងវិញ ដោយក្នុងឆ្នាំ២០២២នេះ ភ្ញៀវទេសចរណ៍មកកម្សាន្តចំនួន **២៩៤.៤១០នាក់** ធៀបឆ្នាំ២០២១ កើនឡើង **៣៥៤,៩៧%** ។

## V- ការងារអគ្គិសនី និងទឹកស្អាត

ខេត្តកំពង់ធំមានអនុស្ថានីយអគ្គិសនីចំនួន ០១ ដែលបានសាងសង់រួចជាស្ថាពរ និងដាក់ឲ្យប្រើប្រាស់ជាផ្លូវការនៅឆ្នាំ២០២០ មានអានុភាពផ្ទុកថាមពលអគ្គិសនីបាន **៥០មេកាវ៉ាត់** ។ ប្រភពផ្តល់ថាមពលអគ្គិសនីមាន២សំខាន់ៗគឺ អនុស្ថានីយខេត្តព្រះវិហារ មាន **១១៥គីឡូវ៉ុល** និងអនុស្ថានីយខេត្តកំពង់ចាម មាន**២៣០គីឡូវ៉ុល** ។ ចំនួនស្ថានីយផលិត និងចែកចាយថាមពលអគ្គិសនីទូទាំងខេត្តមានចំនួន **២១**ស្ថានីយ ។ អត្រាភូមិដែលមានអគ្គិសនីប្រើប្រាស់បានកើនឡើងពី៨៤,២២% នៅឆ្នាំ២០១៨ ដល់ **៩៧.៩១%** នៃភូមិ**៧៦៧**ទូទាំងខេត្ត ។

ដោយឡែកស្ថានីយទឹកស្អាតក្នុងខេត្តមានចំនួន **១៣មូលដ្ឋាន** ដោយគិតមកទល់ពេលនេះ ខេត្តបានភ្ជាប់នាឡិកាស្ទង់ទឹកបានចំនួន **២៦.៥១៨គ្រឿង** ធៀបនឹងឆ្នាំ២០១៨ មានកើនឡើងទ្វេដង ។ មកទល់ពេលនេះ សេវាកម្មទឹកស្អាតបានដាក់បំពង់ទឹកស្អាតបានចំនួន **៨៧៣.០០០ម** ក្នុងភូមិចំនួន **២៣២ភូមិ** ស្មើនឹង **៧៤%** នៃភូមិក្នុងតំបន់សេវាកម្ម **៣១៨ភូមិ** ។

## VI- ការងារសុខាភិបាល

នៅទូទាំងខេត្តកំពង់ធំ មានកន្លែងផ្តល់សេវាសុខាភិបាលរដ្ឋចំនួន **៦៦កន្លែង** ក្នុងនោះ ការិយាល័យសុខាភិបាលស្រុកប្រតិបត្តិចំនួន **៣កន្លែង** មន្ទីរពេទ្យបង្អែកចំនួន **៣កន្លែង** មណ្ឌលសុខភាពចំនួន **៥៦កន្លែង** ប៉ុស្តិ៍សុខភាពចំនួន **៤កន្លែង** ។ ចំណែកកន្លែងផ្តល់សេវាសុខាភិបាលឯកជនមានដូចជាៈ មន្ទីរព្យាបាល **០៧** កន្លែង បន្ទប់ពិគ្រោះជំងឺ **១៤៧កន្លែង** បន្ទប់ថែទាំជំងឺ **៣៣៥កន្លែង** និងឱសថស្ថាន **៧៨កន្លែង** ។

ព្រឹត្តិការណ៍ ២០ កុម្ភៈ ឆ្នាំ២០២០ បានជះឥទ្ធិពលយ៉ាងខ្លាំងដល់ប្រទេសកម្ពុជាទាំងមូល ក៏ដូចជាខេត្តកំពង់ធំ តែដោយអនុវត្តតាមយុទ្ធសាស្រ្ត និងផែនការប្រកបដោយចក្ខុវិស័យខ្ពស់របស់រាជរដ្ឋាភិបាល ខេត្តកំពង់ធំបានគ្រប់គ្រងការរីករាលដាលនៃជំងឺកូវីដ១៩ ប្រកបដោយប្រសិទ្ធភាពខ្ពស់ ដោយមិនអនុញ្ញាតឲ្យមានការរីករាលក្នុងទ្រង់ទ្រាយធំណាមួយឡើយ ។ ទន្ទឹមនឹងនេះ ផ្អែកតាមការណែនាំជាយុទ្ធសាស្រ្តរបស់រាជរដ្ឋាភិបាលក្នុងការបង្កើតភាពស៊ាំក្នុងសហគមន៍ រដ្ឋបាលខេត្តបានផ្តល់វ៉ាក់សាំងការពារជំងឺកូវីដ១៩ ជាប្រចាំជូនប្រជាពលរដ្ឋ និងមន្ត្រីរាជការ នៅតាមមន្ទីរពេទ្យ និងមណ្ឌលសុខភាព ។

## VII- **ការងារអប់រំ យុវជន និងកីឡា**

អនុវត្តតាមគោលនយោបាយបង្កើតសាលាឲ្យនៅជិតផ្ទះ និងគោលនយោបាយឃុំមួយអនុវិទ្យាល័យមួយ សាលារៀនបានកើនឡើងពី**៧៧០សាលា** នៅឆ្នាំ២០១៨ ទៅ**៨០០សាលា** នៅឆ្នាំ២០២២ ។ បច្ចុប្បន្នអគារសិក្សាសរុបមានចំនួន **១.១៣៨ខ្នង** ដែលក្នុងនោះអគារសិក្សាដែលជាអំណោយដ៏ថ្លៃថ្លារបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** មានចំនួន១៧០ខ្នង ។

ការធានាឲ្យការអប់រំមានគុណភាពប្រកបដោយសមធម៌ បរិយាបន្ន និងលើកកម្ពស់ឱកាសសិក្សាពេញមួយជីវិតគឺជាកត្តាចាំបាច់ដែលត្រូវជំរុញអនុវត្តឲ្យបានហ្មត់ចត់ ។ ជាក់ស្តែង អត្រាចូលរៀនរបស់កុមារអាយុ៥ឆ្នាំមានប្រមាណ**៥៩%** លើទិសដៅ **៦១%** ចំណែកអត្រាបញ្ចប់ការសិក្សានៅបឋមសិក្សាមាន **៧៨%** និងអត្រាបញ្ចប់ការសិក្សានៅមធ្យមសិក្សាមាន **៥៦%** ។ ក្នុងរយៈពេល៥ ឆ្នាំចុងក្រោយនេះ បេក្ខជនប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិទទួលបានជោគជ័យក្នុងអត្រា **៧៥%** ។

## VIII- **ការងាររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី**

រដ្ឋបាលខេត្តបានគ្រប់គ្រងការប្រើប្រាស់ដីធ្លី សំណង់ និងដោះស្រាយទំនាស់ដីធ្លី ដោយសម្រេចបាននូវលទ្ធផលជាវិជ្ជមានដូចខាងក្រោម៖

- ការងារចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធអនុវត្តក្នុងស្រុកចំនួន០៧ ដោយបានប្រមូលទិន្នន័យវាស់វែង និងបញ្ចូលទិន្នន័យបាន **៨១.០៣៩ក្បាលដី** និងចែកប័ណ្ណបាន **៦៥.៥០៨ប័ណ្ណ**
- ការងារចុះបញ្ជីដីធ្លីមានលក្ខណៈដាច់ដោយដុំ៖ បានចុះបញ្ជីផ្ទេរសិទ្ធ **១៨.៧៦៨ប័ណ្ណ** ចុះបញ្ជីដាច់ដោយដុំ **២៨៥ប័ណ្ណ** និងចុះបញ្ជីដីរដ្ឋ **៤៧ប័ណ្ណ**
- ការដោះស្រាយទំនាស់ដីធ្លីតាមរយៈគណកម្មាធិការសុរិយោដីបាន **០៧បណ្តឹង** និងកំពុងដោះស្រាយ **២៣ប័ណ្ណ**
- បានផ្តល់លិខិតអនុញ្ញាតសាងសង់សរុបចំនួន **៥០៥គម្រោង** សរុបជាសេវាបង់ចូលថវិការដ្ឋចំនួន **៤០៣.៨០៤.៧២១រៀល** ។

តាមរយៈមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី រដ្ឋបាលខេត្តបានធ្វើពង្រាងផែនទីហេដ្ឋារចនាសម្ព័ន្ធក្រុងស្រុកទាំង០៩បានរួចរាល់ និងបានកសាងផែនការប្រើប្រាស់ដីឃុំសង្កាត់ ដោយបានបោះពុម្ពជាសៀវភៅចែកជូនដល់ឃុំសង្កាត់ចំនួន **៣០ឃុំ/សង្កាត់** ។

## IX- **ការងារសាធារណការ និងផ្លូវលំជនបទ**

ផ្លូវថ្នល់ជាសរសៃឈាមយ៉ាងសំខាន់ក្នុងការដឹកជញ្ជូនកសិផល និងទំនិញសព្វមុខពីខេត្តទៅខេត្ត និងពីខេត្តទៅស្រុក ដែលជំរុញឲ្យមានការអភិវឌ្ឍសេដ្ឋកិច្ចក្នុងខេត្ត ។ បច្ចុប្បន្ន ខេត្តកំពង់ធំ មានផ្លូវជាតិសំខាន់ចំនួន ០៥ ឆ្លងកាត់គឺ ផ្លូវជាតិលេខ ៦ មានប្រវែង ១៤៤គ.ម ផ្លូវជាតិលេខ៦២ ប្រវែង ៣៦គ.ម ផ្លូវជាតិលេខ៧១ ប្រវែង ១៥គ.ម ផ្លូវជាតិលេខ៥០C ប្រវែង១៩គ.ម និងផ្លូវជាតិលេខ៦០B ប្រវែង ៧៤គ.ម ។ កំណាត់ផ្លូវខេត្តក្រាលកៅស៊ូមានចំនួន ១២ខ្សែ ប្រវែងសរុប ២០០គ.ម ។

ការអភិវឌ្ឍផ្លូវលំជនបទត្រូវបានយកចិត្តទុកដាក់ជាចាំបាច់ ដើម្បីភ្ជាប់ទំនាក់ទំនងទាំងផ្នែកសង្គម និងសេដ្ឋកិច្ច និងពីស្រុកទៅឃុំ និងពីឃុំទៅភូមិ ។ នៅទូទាំងខេត្តមានផ្លូវលំជនបទចំនួន ១.១០៨ខ្សែ ក្នុងនោះ

ក្នុងរយៈពេល ៥ឆ្នាំនេះ រដ្ឋបាលខេត្តបានសាងសង់ ជួសជុល និថែទាំផ្លូវលំជនបទបានចំនួន ៧៧ខ្សែ និងបាន កែលម្អផ្លូវទៅជាកម្រាលកៅស៊ូបានចំនួន ១០ខ្សែ។

## X- **ការងារគ្រប់គ្រងអនាម័យ និងបរិស្ថាន**

ដើម្បីរៀបចំឲ្យប្រសើរឡើងនូវសោភ័ណភាព និងអនាម័យបរិស្ថានក្នុងខេត្ត រដ្ឋបាលខេត្តបានរៀបចំទីលានចាក់សម្រាមស្តង់ដារបានចំនួន ០១កន្លែងសម្រាប់ប្រើប្រាស់រួមក្នុងស្រុកកំពង់ស្វាយ និងក្រុងស្ទឹងសែន ដែលមានទំហំ ១៩,៦៦ហ.ត ។ ដោយឡែក ស្រុក៧ ផ្សេងទៀត មានទីលានទុកដាក់សម្រាមមិនទាន់មានលក្ខណៈស្តង់ដារនៅឡើង ។ រដ្ឋបាលខេត្តបាន និងកំពុងសិក្សាទីតាំង និងពិនិត្យមើលលទ្ធភាពដើម្បីបង្កើតឲ្យទៅជាទីលានស្តង់នាពេលអនាគត ។

បច្ចុប្បន្ន ក្រោមឥណទានធនាគារអភិវឌ្ឍអាស៊ី (ADB) រដ្ឋបាលខេត្តកំពុងរៀបចំប្រព័ន្ធលូទឹកកខ្វក់ ទឹកភ្លៀង និងអាងប្រព្រឹត្តកម្មទឹកកខ្វក់ ដោយសម្រេចបានលទ្ធផលបាន ៩៤,២០% ។ គម្រោងនេះ ត្រូវបានអនុវត្ត ក្នុងសង្កាត់ចំនួន០៣ នៃក្រុងស្ទឹងសែន ដែលនឹងត្រូវបញ្ចប់ និងដាក់ឲ្យប្រើប្រាស់ជាផ្លូវការនៅក្នុងឆ្នាំ ២០២៣ នេះផងដែរ ។

## XI- **ទិសដៅអនុវត្តបន្ត**

១.បន្តពង្រឹងការផ្តល់សេវាសាធារណៈតាមរយៈយន្តការច្រកចេញចូលតែមួយ និងបន្តរៀបចំយន្តការច្រកចេញចូលតែមួយឲ្យបានគ្រប់ឃុំ/សង្កាត់ ។

២.ជួយគាំទ្រ និងបង្កើនសមត្ថភាពដល់រដ្ឋបាលក្រុង ស្រុក លើការងារគ្រប់គ្រងធនធាន មនុស្ស នៃរចនាសម្ព័ន្ធរដ្ឋបាលក្រុង/ស្រុក ដែលទើបធ្វើសមាហរណកម្មថ្មី ឆ្នាំ២០២០ ។

៣.ណែនាំ និងពិនិត្យសុវត្ថិភាព សណ្តាប់ធ្នាប់សាធារណៈ សោភ័ណភាព គុណភាព សំណង់ និងផលប៉ះពាល់ផ្សេងៗ ក្នុងការជួសជុល និងកែសម្រួលបណ្តាសំណង់ សាធារណៈ និងសំណង់បេតិកភ័ណ្ឌ

៤.បន្តជំរុញការអនុវត្តច្បាប់ចរាចរណ៍ផ្លូវគោកឲ្យអស់ពីលទ្ធភាពតាមគោលការណ៍របស់គណៈបញ្ជាការដឹកនាំ បញ្ជា ត្រួតពិនិត្យការអនុវត្តច្បាប់ចរាចរណ៍ផ្លូវគោកថ្នាក់ខេត្ត ឲ្យមានប្រសិទ្ធភាព សំដៅកាត់បន្ថយគ្រោះថ្នាក់ចរាចរឲ្យស្ថិតនៅកំរិតទាប ។

៥.បន្តជំរុញការងារបង្ក្រាបសកម្មភាពក្មេងទំនើង និងបទល្មើសគ្រឿងញៀន ។

៦.ជំរុញ និងពិនិត្យលទ្ធភាពនៃការរៀបចំទីលានទុកដាក់សម្រាម និងធ្វើអាងប្រព្រឹត្តិកម្មសំណល់រាវតាមលក្ខណៈបច្ចេកទេសឲ្យបានគ្រប់ក្រុង/ស្រុក ។

៧.បន្តពង្រឹកការគ្រប់គ្រងធនធានធម្មជាតិ ។

៨.បន្តជំរុញការអនុវត្តអនុសាសន៍របស់សម្តេចតេជោកាលពីថ្ងៃទី០៣ ខែកក្កដា ឆ្នាំ២០២២ ។